# ក

# មាតិកា

## I-ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


០៣-៩-២០០៤ -ព្រះរាជក្រឹត្យ នស/រកត/០៩០៤/២៣៨ ស្តីពីការដាក់អោយចូលនិវត្តន៍ក្នុងក្របខ័ណ្ឌរដ្ឋបាលសាធារណៈ មន្ត្រីថ្នាក់ដឹកនាំក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ចំនួន ០៤ រូប ២០១៨

០៣-៩-២០០៤ -ព្រះរាជក្រឹត្យ នស/រកត/០៩០៤/២៣៩ ស្តីពីការតែងតាំងឯកឧត្តម **ឈឹម នខាយ** ជាទីប្រឹក្សារបស់សម្តេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា ទទួលបន្ទុកការងារច្បាប់អន្តរជាតិ និងកិច្ចសហប្រតិបត្តិការ មានឋានៈស្មើ **រដ្ឋលេខាធិការ** ដោយពុំទទួលប្រាក់បៀវត្ស ២០១៩

០៣-៩-២០០៤ -ព្រះរាជក្រឹត្យ នស/រកត/០៩០៤/២៤០ ស្តីពីការតម្លើងឋានន្តរសក្តិជូននាយទាហានជាន់ខ្ពស់ ចំនួន ០២ រូប ២០២០

០៣-៩-២០០៤ -ព្រះរាជក្រឹត្យ នស/រកត/០៩០៤/២៤១ ស្តីពីការតែងតាំង និងតម្លើងឋានន្តរសក្តិជូនឯកឧត្តម **ខួន ស្រេង** ពីវរសេនីយ៍ឯក ទៅជា **ឧត្តមសេនីយ៍ត្រី** នាយនគរបាលជាតិជាន់ខ្ពស់ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ ២០២១

០៣-៩-២០០៤ -ព្រះរាជក្រឹត្យ នស/រកត/០៩០៤/២៤២ ស្តីពីការតែងតាំងឯកឧត្តមចំនួន ០៣ រូប ជាទីប្រឹក្សាអមក្រសួងពត៌មាន ២០២២

០៧-៩-២០០៤ -ព្រះរាជក្រឹត្យ នស/រកត/០៩០៤/២៤៤ ស្តីពីការតែងតាំងថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា ចំនួន ០២ រូប ២០២៤

០៧-៩-២០០៤ -ព្រះរាជក្រឹត្យ នស/រកត/០៩០៤/២៤៥ ស្តីពីការតម្លើងឋានៈជូនមន្ត្រីនៃធនាគារជាតិនៃកម្ពុជា ចំនួន ០៤ រូប ២០២៥

០៧-៩-២០០៤ -ព្រះរាជក្រឹត្យ នស/រកត/០៩០៤/២៤៦ ស្តីពីការតែងតាំងឯកឧត្តម **ម៉ុម សារឿន** ជាទីប្រឹក្សារបស់សម្តេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា ទទួលបន្ទុកការងារសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានឋានៈស្មើ **រដ្ឋលេខាធិការ** ដោយពុំទទួលប្រាក់បៀវត្ស ២០២៦

០៧-៩-២០០៤ -ព្រះរាជក្រឹត្យ នស/រកត/០៩០៤/២៤៧ ស្តីពីការតែងតាំងឯកឧត្តម **ស ខាន់ធី** ជាជំនួយការសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ **អគ្គនាយក** ២០២៧

០៧-៩-២០០៤ -ព្រះរាជក្រឹត្យ នស/រកត/០៩០៤/២៤៨ ស្តីពីការតម្លើងឋានន្តរសក្តិថ្នាក់ **ឧត្តមសេនីយ៍ឯក** ជូនឧត្តមសេនីយ៍ទោ **អ៊ិន ចន្ថា** នាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ២០២៨

០៧-៩-២០០៤ -ព្រះរាជក្រឹត្យ នស/រកត/០៩០៤/២៤៩ ស្តីពីការបញ្ចូលក្របខ័ណ្ឌ ក្នុងកងយោធពលខេមរភូមិន្ទ និងប្រគល់ឋានន្តរស័ក្តិថ្នាក់ឧត្តមសេនីយ៍ត្រី ជូនឯកឧត្តមចំនួន ០២ រូប ២០២៩

០៧-៩-២០០៤ -ព្រះរាជក្រឹត្យ នស/រកត/០៩០៤/២៥០ ស្តីពីការតែងតាំងឯកឧត្តម **អ៊ុក ស៊ីសាន** ជា **អគ្គនាយក** នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុក្រសួងទេសចរណ៍ ២០៣០

០៧-៩-២០០៤ -ព្រះរាជក្រឹត្យ នស/រកត/០៩០៤/២៥១ ស្តីពីការតែងតាំងលោកជំទាវ **ខុង សាន** ជា **អនុរដ្ឋលេខាធិការ** ក្រសួងទេសចរណ៍ ជំនួស ឯកឧត្តម **អ៊ុក ស៊ីសាន** ដែលត្រូវទទួលមុខតំណែងថ្មី ២០៣១

០៧-៩-២០០៤ -ព្រះរាជក្រឹត្យ នស/រកត/០៩០៤/២៥២ ស្តីពីការតែងតាំង សមាសភាពថ្នាក់ដឹកនាំ អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិទេសចរណ៍កម្ពុជា ២០៣២

## II.ក្រុមប្រឹក្សាធម្មនុញ្ញ

០៧-៩-២០០៤ -សំណុំរឿង លេខ : ០៨៣/០០៦/២០០៤ ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០៤
-សេចក្តីសំរេច លេខ: ០៦១/០០៣/២០០៤ កបធ.ច ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៤ ២០៣៣

## III.រាជរដ្ឋាភិបាល

០៦-៩-២០០៤ -សេចក្តីសំរេចលេខ ៥៤ សសរ ស្តីពីការកែសំរួលសមាសភាពគណៈកម្មការការពារអង្គជំនុំជំរះវិសាមញ្ញ ២០៣៥

## IV.ការចារបណ្ណាក្រសួង

### ១.ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

០៧-៩-២០០៤ -សេចក្តីជូនដំណឹងលេខ ០១៧ សហវ.ពដ ស្តីពីបែបបទបង់ប្រាក់ពន្ធអាករសម្រាប់អ្នកជាប់ពន្ធមធ្យម

### ២.ទីស្តីការរដ្ឋមន្ត្រីក្រសួងសុខាភិបាល

០៧-៩-២០០៤ -ប្រកាសលេខ ៨៤១ អបស/ឱអបស ស្តីពីទីតាំងឱសថស្ថានរងក្នុងរាជធានីភ្នំពេញ ២០៣៨

### ៣.ទីស្តីការរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

០២-៩-២០០៤ -ប្រកាសលេខ ១៥០ ប្រក ស្តីពីការរៀបចំគណៈកម្មការជំរឿន និង គ្រប់គ្រងជនបរទេស ២០៤០

### ៤.ទីស្តីការរដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច

០១-៩-២០០៤ -ប្រកាសលេខ ០៩៩/០៤៩.រ.ព.អ.ប្រក ស្តីពីការតែងតាំងនាយកកម្មវិធីកន្សោមអាទិភាពរួមទាំងក្រុមការងារ ដើម្បីដឹកនាំ គ្រប់គ្រង និងជំរុញដំណើរការកន្សោមអាទិភាព ២០៤៤

ព្រះរាជក្រឹត្យ

នស/រកត/០៩០៤/៧៣៨

យើង

ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែមេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានដាក់អោយចូលនិវត្តន៍ក្នុងក្របខ័ណ្ឌរដ្ឋបាលសាធារណៈ មន្ត្រីថ្នាក់ដឹកនាំក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដូចខាងក្រោម :

| | | |
|---|---|---|
| ១. ឯកឧត្តម | ហោ ណាំហុង | ឋានន្តរសក្តិ ឧត្តមមន្ត្រីថ្នាក់លេខ ១ |
| ២ ឯកឧត្តម | អ៊ុច គីមអន | ឋានន្តរសក្តិ ឧត្តមមន្ត្រីថ្នាក់លេខ ១ |
| ៣ លោកជំទាវ | ស៊ុន សារឿន | ឋានន្តរសក្តិ ឧត្តមមន្ត្រីថ្នាក់លេខ ២ |
| ៤ ឯកឧត្តម | សៀង ឡាប្រេស្ស | ឋានន្តរសក្តិ ឧត្តមមន្ត្រីថ្នាក់លេខ ៤ |

មាត្រា ២ : ថ្នាក់ដឹកនាំក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដែលត្រូវដាក់អោយចូលនិវត្តន៍ ដូចមានរាយនាមក្នុងមាត្រាទី ១ ខាងលើ នៅតែបន្តការងារក្នុងមុខដំណែងនយោបាយដដែលរហូតដល់មានការសំរេចជាថ្មី ។

មាត្រា ៣ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តព្រះរាជក្រឹត្យនេះអោយបានសំរេច ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់តាំងពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០០៤*

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ជា ស៊ីម

រ.ស.ល.០៤០៩.៧៣៩

លេខ ១៩១ ចល ហត្ថលេខា និងព្រះរាជលញ្ឆករ

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ២០០៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុំ ម៉ានិត

សណ្ហានី តាន់

# ព្រះរាជក្រឹត្យ

នស / រកត / ០៩០៤ / ២៣៩

## យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ១៩៩៣
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែមីនា ឆ្នាំ ១៩៩៩ ដែលប្រកាស់បង្គាប់អោយប្រើជាផ្លូវការ នូវច្បាប់រដ្ឋធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ០៤ ខែមីនា ឆ្នាំ ១៩៩៩
- បានទ្រង់យល់ព្រះរាជក្រឹត លេខ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី ១១ ខែមីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់តែងតាំង ប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- យោងតាមសំណូមពរចាំបាច់នៃការងារ

## ត្រាស់បង្គាប់

**មាត្រា ១:** តែងតាំងឯកឧត្តម **លឹម ឆខាយ** ជាទីប្រឹក្សារបស់សម្តេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា ទទួលបន្ទុកការងារច្បាប់អន្តរជាតិ និងកិច្ចសហប្រតិការ មានឋានៈស្មើ **រដ្ឋលេខាធិការ** ដោយពុំទទួលប្រាក់បៀវត្ស ។

**មាត្រា ២:** ប្រធានព្រឹទ្ធសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាត្រូវទទួលបន្ទុកអនុវត្ត ព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣:** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៤
ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់
ប្រមុខរដ្ឋស្តីទី

៣រល. ០៤០៩. ៤០

ហត្ថលេខា និងព្រះរាជលញ្ឆករ
ជា ស៊ីម

លេខ: ១៩៦. ចល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៤
អគ្គលេខាធិការរាជរដ្ឋាភិបាល
ឧកញ៉ា ស៊ី តាន់

# ព្រះរាជក្រឹត្យ

នស/រកត ០៩០៤/២៤០

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០៧០៤ / ០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានាដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/ នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃ ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសំរួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គមេបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ .-

ក-ថ្នាក់ឧត្តមសេនីយ៍ទោ : ១ រូប

១. ឧត្តមសេនីយ៍ត្រី អ៊ុក ខឿន អត្តលេខ ០០១២៣៩ ជំនួយការសម្តេចប្រធានព្រឹទ្ធសភា និងជាមេបញ្ជាការរងកងពលតូចលេខ ៧០

ខ- ថ្នាក់ឧត្តមសេនីយ៍ត្រី : ១ រូប

១. វរៈសេនីយ៍ឯក ខា សុមេធី អត្តលេខ ០០៣៣៧៦ នាយករងខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភា

មាត្រា ២ .-

សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ .-

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី០៧ ខែ កញ្ញា ឆ្នាំ ២០០៤

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

ពរស.០៤០៩.២៤១

លេខ ១៩៧ ចល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០០៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាងី គាន់

ព្រះរាជក្រឹត្យ

នស/រកត/០៩០៤/២៤១

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០៧០៤ / ០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/ នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃ ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃប្រកខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១.-

តែងតាំង ឯកឧត្តម ខួន ស្រេង ជាជំនួយការ សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ អគ្គនាយក ។

មាត្រា ២.-

តម្លើងឋានន្តរសក្តិជូន ឯកឧត្តម ខួន ស្រេង អត្តលេខ ០៣៥២ ពីវរសេនីយ៍ឯក ទៅជាឧត្តមសេនីយ៍ត្រី នាយនគរបាលជាតិជាន់ខ្ពស់ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ ។

មាត្រា ៣.-

សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវ ព្រះរាជក្រឹត្យនេះ ។

មាត្រា ៤.-

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០០៤

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

៣រល. ០៤០៩. ៧៤៤

លេខ: ១៧៣ ចល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែ កញ្ញា ឆ្នាំ២០០៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

ណាគី តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៩០៤/៧៤៧

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពត៌មាន
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

មាត្រា ១._

តែងតាំង :

១_ឯកឧត្តម សុខ ចំរើន ជាទីប្រឹក្សាអមក្រសួងពត៌មាន ទទួលបន្ទុកផ្នែកបច្ចេកទេសប្រព័ន្ធខ្សែកាប មានឋានៈស្មើ អគ្គនាយក ។

២_ឯកឧត្តម អ៊ុក គឹមសេង ជាទីប្រឹក្សាអមក្រសួងពត៌មាន ទទួលបន្ទុកកិច្ចការសារពត៌មាន មានឋានៈស្មើ អគ្គនាយក ។

៣_ឯកឧត្តម ឡុង សេង ជាទីប្រឹក្សាអមក្រសួងពត៌មាន ទទួលបន្ទុកសំរួលកិច្ចការមន្ទីរពត៌មានខេត្ត ក្រុង មានឋានៈស្មើ អគ្គនាយក ។

មាត្រា ២._

សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា   ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣._

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន   ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ,  ថ្ងៃទី ០៣ ខែកញ្ញា ឆ្នាំ ២០០៤*

ក្នុងព្រះបរមនាម និង តាមព្រះរាជបញ្ជាស់បន្ទាប់

ប្រមុខរដ្ឋស្តីទី

ពរស.០៤០៩.២៤៣              ហត្ថលេខា  និងព្រះរាជលញ្ឆករ

ជា  ស៊ីម

លេខ: ១៩៧ ចល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ,ថ្ងៃទី០៧ ខែកញ្ញា  ឆ្នាំ២០០៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាង  តាន់

# ព្រះរាជក្រឹត្យ

យើង

នស/រកត/០៩០៤/២៤៤

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃធនាគារជាតិ នៃកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១.-**

តែងតាំងថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា ចំនួន ០២ រូប ដូចមានរាយនាមខាងក្រោម :

១- ឯកឧត្តម ជា ចាន់តូ ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា មានឋានៈស្មើ ទេសរដ្ឋមន្ត្រី

២- លោកជំទាវ នាវ ចន្ទថាណា ជាអគ្គទេសាភិបាលរងធនាគារជាតិនៃកម្ពុជា មានឋានៈស្មើ រដ្ឋលេខាធិការ ជំនួស ឯកឧត្តម អេង ថៃយសាន ដែលត្រូវទៅបំពេញភារកិច្ចថ្មី ។

**មាត្រា ២.-**

បទប្បញ្ញត្តទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣.-**

សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤.-**

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៤

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

អគ្គលេខា និងព្រះរាជលញ្ចករ

ជា ស៊ីម

ពាល.០៤០៩.២៤៤

លេខ: ១៩៣ ចល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី០៩ ខែ កញ្ញា ឆ្នាំ២០០៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

[illegible] តាន់

# ព្រះរាជក្រឹត្យ

យើង

នស/រកត/០៩០៤/២៤៥

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃធនាគារជាតិ នៃកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១.-**

តម្លើងឋានៈជូនមន្ត្រីជាន់ខ្ពស់នៃធនាគារជាតិនៃកម្ពុជា ចំនួន ០៤ រូប ដូចមានរាយនាមខាងក្រោម :

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | ស៊ុំ សន្និសិទ្ធ | អគ្គលេខាធិការធនាគារជាតិនៃកម្ពុជា | មានឋានៈស្មើ រដ្ឋលេខាធិការ |
| ២- ឯកឧត្តម | ជា យ៉ាន | អគ្គពិនិត្យធនាគារជាតិនៃកម្ពុជា | មានឋានៈស្មើ រដ្ឋលេខាធិការ |
| ៣- ឯកឧត្តម | នៀង សេង | អគ្គបេឡា ធនាគារជាតិនៃកម្ពុជា | មានឋានៈស្មើ រដ្ឋលេខាធិការ |
| ៤- លោកជំទាវ | តាល់ ណៃអ៊ីម | អគ្គនាយក ធនាគារជាតិនៃកម្ពុជា | មានឋានៈស្មើ រដ្ឋលេខាធិការ |

**មាត្រា ២.-**

សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣.-**

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៤

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

.ការ. ០៩០៤.២៤៦

លេខៈ ១៩៤.ចល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ២០០៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុំ ម៉ារ៉ាន់

# ព្រះរាជក្រឹត្យ

នស / រកត / ០៩០៤ / ៧៤៦

## យើង

ព្រះបាទសម្ដេចព្រះ នរោត្ដម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្ដម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ១៩៩៣
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែមីនា ឆ្នាំ ១៩៩៩ ដែលប្រកាសបង្គាប់អោយប្រើជាផ្លូវការ នូវច្បាប់រដ្ឋធម្មនុញ្ញ ស្ដីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ០៤ ខែមីនា ឆ្នាំ ១៩៩៩
- បានទ្រង់យល់ព្រះរាជក្រឹត លេខ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី ១១ ខែមីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់តែងតាំង ប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- យោងតាមសំណូមពរចាំបាច់នៃការងារ

## ត្រាស់បង្គាប់

មាត្រា ១: តែងតាំងឯកឧត្ដម ម៉ូម សារឿន ជាទីប្រឹក្សារបស់សម្ដេច ជា ស៊ីម ប្រធានព្រឹទ្ធសភា ទទួលបន្ទុកការងារសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានឋានៈស្មើ រដ្ឋលេខាធិការ ដោយពុំទទួលប្រាក់បៀវត្ស ។

មាត្រា ២: ប្រធានព្រឹទ្ធសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាត្រូវទទួលបន្ទុកអនុវត្ត ព្រះរាជក្រឹត្យនេះ។

មាត្រា ៣: ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ដលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៤

គ្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្ដីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

៣រល.០៩០៩.៧៤៧

លេខ: ៤៧០៦ ចល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ២០០៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាវ តាន់

ព្រះរាជក្រឹត្យ

នស/រកត/០៩០៤/២៤៧

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០៧០៤ / ០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/ នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ ..

តែងតាំងឯកឧត្តម ស ខាន់ឌី ជាជំនួយការសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើអគ្គនាយក ។

មាត្រា ២ ..

សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ ..

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ ២០០៤

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

៣៧-០៤០៩.២៤៨

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

លេខ: ១៩៧ ចល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី១៥ ខែ កញ្ញា ឆ្នាំ២០០៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

សាន់ឌី តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៩០៤/២៤៨

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០៧០៤ / ០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានាដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/ នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃ ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសំរួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គមេបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ .-

តម្លើងឋានន្តរសក្តិថ្នាក់ឧត្តមសេនីយ៍ឯក ជូនឧត្តមសេនីយ៍ទោ អ៊ិន ចន្ថា អត្តលេខ ០០០៤៧០ នាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ។

មាត្រា ២ .-

សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ .-

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ ២០០៤

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់
ប្រមុខរដ្ឋស្តីទី

កាល-០៤០៩.២៤៩

លេខៈ ៦៩០ ចល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៤
អគ្គលេខាធិការរាជរដ្ឋាភិបាល

ណាំឌី តាន់

ហត្ថលេខា និងព្រះរាជលញ្ឆករ
ជា ស៊ីម

# ព្រះរាជក្រឹត្យ

នស / រកត / ០៩០៤ / ២៤៩

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស /រកម / ០៧០៤ / ០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/ នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស / រកប / ០១៩៦ / ០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ .-**

ត្រូវបានបញ្ចូលក្របខ័ណ្ឌ ក្នុងកងយោធពលខេមរភូមិន្ទ និងប្រគល់ឋានន្តរស័ក្តិ ថ្នាក់ឧត្តមសេនីយត្រី ជូនឯកឧត្តម ចំនួនពីររូប ដូចមានរាយនាមខាងក្រោម :

១- ឯកឧត្តម ឃាស រដ្ឋា

២- ឯកឧត្តម ពេជ្រ សុជេដ្ឋា

**មាត្រា ២ .-**

សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ .-**

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៤*

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

ពល.០៤០៩.៧៥០

លេខ: ៦៩៩ ចល

ដើម្បីចម្លងចែកជូន

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ២០០៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាវ តាន់

ព្រះរាជក្រឹត្យ

នស/រកត/០៩០៤/២៥០

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម/ ០៧០៤ / ០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/ នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦ / នស / ៩៤ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម នស / រកម / ០១៩៦ / ១៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ការបង្កើតក្រសួងទេសចរណ៍
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ .-

តែងតាំងឯកឧត្តម រិទ្ធ ស៊ីផាន ជា អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងទេសចរណ៍។

មាត្រា ២ .-

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ .-

សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ .-

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ ២០០៤

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ជា ស៊ីម

រ.ល.ច.០៤០៩.២៥១

ហត្ថលេខា និងព្រះរាជលញ្ឆករ

លេខៈ ៤០០ ចល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០០៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាង ឪ ត្រាន

# ព្រះរាជក្រឹត្យ

នស/រកត/០៩០៤/២៩៧

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០៧០៤ / ០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/ នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ .-**

តែងតាំងលោកជំទាវ ខូច សាខ ជា អនុរដ្ឋលេខាធិការ ក្រសួងទេសចរណ៍ ជំនួស ឯកឧត្តម អ៊ុក ស៊ីផាន ដែលត្រូវទទួលបុនតំណែងថ្មី ។

**មាត្រា ២ .-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣ .-**

សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤ .-**

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ ២០០៤*

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

**ប្រមុខរដ្ឋស្តីទី**

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

តារ.០៩០៩.២៥២

លេខ: ២០១ ចល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

ណារី តាន់

# ព្រះរាជក្រឹត្យ

នស / រកត / ០៩០៤ / ៧៤៧

## យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានាឱ្យដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១.-**

តែងតាំងសមាសភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិទេសចរណ៍កម្ពុជា :

១-ឯកឧត្តម សូ មារ៉ា ជាអគ្គលេខាធិការ មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន

២-ឯកឧត្តម ញឹម ខេមរា ជាអគ្គលេខាធិការរង មានឋានៈស្មើ អគ្គនាយក

៣-ឯកឧត្តម សួស យ៉ារ៉ា ជាអគ្គលេខាធិការរង មានឋានៈស្មើ អគ្គនាយក

**មាត្រា ២.-**

សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣.-**

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ ២០០៤

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

ចរល.០៤០៩.៧៤៣

លេខ ១៩៥ ចល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ២០០៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាងី តាន់

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ០៨៣/០០៦/២០០៤

ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០៤

**សេចក្តីសម្រេច**

លេខ : ០៦១ /០០៣/២០០៤ កបធ.ច

ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៤

## ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញលិខិត ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៤ របស់ក្រុមតំណាងរាស្ត្រចំនួន ១៦ រូប សុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញ បកស្រាយមាត្រា ៧ នៃរដ្ឋធម្មនុញ្ញ ក្នុងករណីព្រះមហាក្សត្រដាក់រាជសម្បត្តិ

-បានឃើញឯកសារទទួលពីរដ្ឋសភាទាក់ទងនឹងការពិភាក្សារបស់សភាធម្មនុញ្ញ លើមាត្រា៧ នៃរដ្ឋធម្មនុញ្ញ

**ក្រោយពីបានស្តាប់សេចក្តីរាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

-យល់ឃើញថា តំណាងរាស្ត្រ ១៦ រូប គឺលើសពីមួយភាគដប់នៃចំនួនតំណាងរាស្ត្រនៅរដ្ឋសភា បានធ្វើលិខិតមួយមកឯកឧត្តមប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៤ ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញ បកស្រាយមាត្រា ៧ នៃរដ្ឋធម្មនុញ្ញ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០៤ វេលាម៉ោង ១៤ :២៣ នាទី ។ ចំនួន ១៦ រូប នេះ គឺគ្រប់គ្រាន់តាមបទបញ្ញត្តិនៃមាត្រា ១៤១ ថ្មីនៃរដ្ឋធម្មនុញ្ញហើយ ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញ អាចទទួលសំណើសុំបកស្រាយនេះមកពិនិត្យបាន ដោយស្របតាមមាត្រា ១៣៦ ថ្មីនៃរដ្ឋធម្មនុញ្ញ និងមាត្រា ១៥ មាត្រា ១៨ នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/ ០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ផងដែរ ។

-យល់ឃើញថា លិខិតតំណាងរាស្ត្រ សុំឱ្យបកស្រាយមាត្រា ៧ នៃរដ្ឋធម្មនុញ្ញ ដោយដាក់ជាបញ្ហា ក្នុងករណីព្រះមហាក្សត្រដាក់រាជសម្បត្តិ " *ក្រោយពីមានព្រះរាជសាររបស់ព្រះមហាក្សត្រ ស្តីពីព្រះរាជហឫទ័យចង់ដាក់រាជសម្បត្តិជាញឹកញាប់នោះមក មានការបកស្រាយខុសៗគ្នា រវាងនាយករដ្ឋមន្ត្រី និង ក្រុមអ្នកច្បាប់មួយចំនួនស្តីពីការដាក់រាជសម្បត្តិនេះ ។* " ពាក់ព័ន្ធសំខាន់លើវាក្យខ័ណ្ឌទី ២ នៃមាត្រា ៧ នៃរដ្ឋធម្មនុញ្ញដែលចែងថា " *ព្រះមហាក្សត្រ ទ្រង់ជាព្រះប្រមុខរដ្ឋមួយជីវិត* " ។ ត្រង់នេះ មានន័យថា ព្រះមហាក្សត្រទ្រង់គ្រងរាជសម្បត្តិ និងទ្រង់ជាព្រះប្រមុខរដ្ឋមួយជីវិត ។ ព្រះរាជតួនាទី ក្នុងការគ្រងរាជសម្បត្តិ ជាប់ជាមួយព្រះរាជតួនាទី ជាព្រះប្រមុខរដ្ឋ ដោយមិនអាចផ្តាច់ចេញពីគ្នាបានទេ ។ ដូច្នេះ ព្រះមហាក្សត្រទ្រង់គ្រងរាជសម្បត្តិ និង ទ្រង់ជាព្រះប្រមុខរដ្ឋមួយជីវិត គឺរជ្ជកាលរបស់ព្រះមហាក្សត្រត្រូវបានកំណត់ចាប់ពីពេលដែលព្រះអង្គឡើងគ្រងរាជសម្បត្តិ រហូតដល់ពេលព្រះអង្គចូលទិវង្គត ។

-យល់ឃើញថា សភាធម្មនុញ្ញបានអនុម័តមាត្រា ១២ មាត្រា ១៣ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឱ្យមានការជ្រើសតាំងព្រះមហាក្សត្រថ្មី ក្នុងករណីព្រះមហាក្សត្រ សោយទិវង្គតតែប៉ុណ្ណោះ ។

-យល់ឃើញថា ការដាក់រាជសម្បត្តិ មិនមានចែងក្នុងរដ្ឋធម្មនុញ្ញទេ ។

**សំរេច**

**មាត្រា ១.-** មាត្រា ៧ នៃរដ្ឋធម្មនុញ្ញ ត្រូវបកស្រាយដូចមានបញ្ជាក់ក្នុងមូលបទខាងលើ ។

**មាត្រា ២.-** សេចក្តីសំរេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៤ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ និង ជាសេចក្តីសំរេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៤

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

ប៊ិន ឈិន

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥៤ ស.ស.រ

## សេចក្តីសំរេច

## ស្តីពី

## ការកែសំរួលសមាសភាពគណៈកម្មការការពារអង្គជំនុំជំរះវិសាមញ្ញ

### រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១២ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ ស្តីពីការប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតអោយមានអង្គជំនុំជំរះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់ក្តីអតីតមេដឹកនាំខ្មែរក្រហម
- បានឃើញកិច្ចព្រមព្រៀងស្តីពីការជំនុំជំរះក្តីអតីតមេដឹកនាំខ្មែរក្រហមរវាងរាជរដ្ឋាភិបាល និងអង្គការសហប្រជាជាតិ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៣
- បានឃើញសេចក្តីសំរេចលេខ១៣ សសរ ចុះថ្ងៃទី២៤ ខែមិនា ឆ្នាំ២០០៤ ស្តីពីការបង្កើតគណៈកម្មការដឹកនាំការងារធានាសន្តិសុខសំរាប់កិច្ចដំណើរការជំនុំជំរះក្តីអតីតមេដឹកនាំខ្មែរក្រហម
- យោងតាមការចាំបាច់ និងតាមសំណើរបស់គណៈកម្មការការពារអង្គជំនុំជំរះវិសាមញ្ញ (គ.ក.អ.វ)

### សំរេច

**ប្រការ ១ :** រៀបចំកែសំរួលសមាសភាព គ.ក.អ.វ មួយចំនួនដែលមានចែងនៅក្នុងប្រការ១ នៃ

សេចក្ដីសំរេចលេខ ១៣ ស.ស.រ ចុះថ្ងៃទី២៤ ខែមិនា ឆ្នាំ២០០៤ ដូចខាងក្រោម :

- ប្រគល់ភារកិច្ចជូន ឯកឧត្តម ឧត្តមសេនីយ៍ឯក **គៀង សាវុធ** អនុរដ្ឋលេខាធិការ ក្រសួងការពារជាតិ ជាអនុប្រធាន គ.ក.អ.វ ជំនួសឯកឧត្តម **នៅ សំ** ។
- ប្រគល់ភារកិច្ចជូន ឯកឧត្តម **ឌុច សុន** អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ ជាសមាជិក គ.ក.អ.វ ជំនួសឯកឧត្តម **អ៊ិច សារូ** ។
- ឯកឧត្តម ដុំ **គឹមឡេង** អគ្គលេខាធិការរង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក គ.ក.អ.វ ។

**ប្រការ ២ :** ប្រធានគណៈកម្មការការពារអង្គជំនុំជំរះវិសាមញ្ញ (គ.ក.អ.វ) មានភារកិច្ចអនុវត្តសេចក្ដីសំរេចនេះ ។

**ប្រការ ៣ :** សេចក្ដីសំរេចនេះ មានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០១៦៥ សហវ.ការ

# សេចក្តីជូនដំណឹង

## ស្តីពី

## បែបបទបង់ប្រាក់ពន្ធអាករសម្រាប់អ្នកជាប់ពន្ធមធ្យម

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ លោក/លោកស្រី ដែលជាបណ្ណាធិការ ឬកម្មសិទ្ធិករ សហគ្រាស ក្រុមហ៊ុន ទាំងអស់ឱ្យបានជ្រាបថា ចាប់តាំងពីខែវិច្ឆិកា ឆ្នាំ២០០១ រហូតមក សហគ្រាស ក្រុមហ៊ុន ដែលជាអ្នកជាប់ពន្ធស្ថិតក្រោមការគ្រប់គ្រងរបស់អង្គភាពគ្រប់គ្រងអ្នកជាប់ពន្ធធំ នៃការិយាល័យប្រមូលពន្ធតាមរបបពិត នៅរាជធានីភ្នំពេញ បានធ្វើការបង់ប្រាក់ពន្ធអាករនានានៅធនាគារជាតិនៃកម្ពុជា ។

ក្នុងគោលដៅកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ចាប់ពីថ្ងៃទី០១ ខែតុលា ឆ្នាំ២០០៤ តទៅ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមកំណត់បែបបទនៃការបង់ប្រាក់ពន្ធអាករនានារបស់ សហគ្រាស ក្រុមហ៊ុន ទាំងអស់ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់អង្គភាពគ្រប់គ្រងអ្នកជាប់ពន្ធមធ្យមនៃការិយាល័យប្រមូលពន្ធតាមរបបពិតនៅរាជធានីភ្នំពេញ ដូចខាងក្រោម :

១- ការបង់ប្រាក់ពន្ធអាករជាសាច់ប្រាក់ ( Cash Payment ) ត្រូវធ្វើដោយផ្ទាល់នៅធនាគារជាតិនៃកម្ពុជា ។

២- ការបង់ប្រាក់ពន្ធអាករដោយប្រើមូលប្បទានបត្រ ( Cheque ) អាចធ្វើបាននៅធនាគារជាតិនៃកម្ពុជា ឬនៅការិយាល័យប្រមូលពន្ធតាមរបបពិតក៏បាន ។

៣- ការបង់ប្រាក់ពន្ធអាករដោយវិធីផ្ទេរគណនីធនាគារ ( Transfer of Bank Account ) ត្រូវផ្ទេរចូលក្នុងគណនីនាយកដ្ឋានពន្ធដារនៅធនាគារជាតិនៃកម្ពុជាដូចខាងក្រោម :

- ប្រាក់រៀល : គណនីលេខ 0100-39.1211-T112
- ប្រាក់ដុល្លារអាមេរិក : គណនីលេខ 0102-35.1211-T127 ។

ក្រោយការបង់ប្រាក់ពន្ធអាករ លោក/លោកស្រីត្រូវយកបង្កាន់ដៃទទួលប្រាក់ពន្ធដែលចេញដោយធនាគារជាតិនៃកម្ពុជាភ្ជាប់ជាមួយនិងលិខិតប្រកាសសារពើពន្ធ ដាក់ជូនការិយាល័យប្រមូលពន្ធតាមរបបពិត ទៅតាមការកំណត់ដូចមានចែងក្នុងច្បាប់ស្តីពីសារពើពន្ធ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោក/លោកស្រី អនុវត្តតាមខ្លឹមសារនៃលិខិតជូនដំណឹងនេះឱ្យបានល្អប្រសើរ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ២០០៤

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
[illegible]

គាត់ ឈន់

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣ ៤២៧ ៧៩៨

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

លេខ 841 ស.ស.ក/ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី 7 ខែ កញ្ញា ឆ្នាំ២០០4

# ប្រកាស

ស្តីពី

## ទីតាំងនៃឱសថស្ថានរងក្នុងរាជធានីភ្នំពេញ

## រដ្ឋមន្ត្រី ក្រសួងសុខាភិបាល

-បានឃើញ រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ កក្កដា ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។

-បានឃើញ ព្រះរាជក្រម នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤-០១-៩៦ ប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសុខាភិបាល ។

-បានឃើញ ព្រះរាជក្រម ជស-រកម-០៦៩៦/០២ ចុះថ្ងៃទី ១៧ មិថុនា ១៩៩៦ ប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងឱសថ ។

-បានឃើញ អនុក្រឹត្យលេខ ៦៧ អនក្រ-បក ចុះថ្ងៃទី ២៧-១០-៩៧ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល ។

-បានឃើញ ប្រកាសរបស់ក្រសួងសុខាភិបាល លេខ ១៥៥ អបស/ឱអបស ចុះថ្ងៃទី ២១ មីនា ២០០០ ស្តីពី ការកែសំរួល ប្រកាសលេខ ៩៣៧ សនបឱ របស់ក្រសួងសុខាភិបាល ស្តីពីបែបបទនិងល័ក្ខខ័ណ្ឌក្នុងការសុំបើកឬបិទឬប្តូរទីតាំងនៃគ្រឹះស្ថានលក់ឱសថ ។

### សំរេច

**ប្រការ១** : ការសុំបើក និងការសុំប្តូរទីតាំងនៃឱសថស្ថានរងប្រភេទ (ក) និង (ខ) ក្នុងខ័ណ្ឌចំការមន, ខ័ណ្ឌដូនពេញ ខ័ណ្ឌ ៧មករា និង សង្កាត់១ចំនួន នៅក្នុងខ័ណ្ឌទួលគោកដូចជា សង្កាត់ ផ្សារដេប៉ូ១ , ផ្សារដេប៉ូ២ , ទឹកល្អក់១ , ទឹកល្អក់២, ទឹកល្អក់៣ បឹងសាឡាង និងផ្សារដើមគរ ត្រូវផ្អាកចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ដោយបច្ចុប្បន្ន ឱសថស្ថានរងប្រភេទ (ក) និង (ខ) មានចំនួនគ្រប់គ្រាន់តាមសមាមាត្រកំណត់ ។

**ប្រការ២** : ការសុំបើក និង ការសុំប្តូរទីតាំងនៃឱសថស្ថានរងប្រភេទ (ក) និង (ខ) អាចអនុញ្ញាតបាន ប្រសិនបើទីតាំងសុំបើក ឬ សុំផ្លាស់នោះ ស្ថិតក្នុងខ័ណ្ឌមានជ័យ, ខ័ណ្ឌឫស្សីកែវ ,ខ័ណ្ឌដង្កោ , សង្កាត់បឹងកក់១ និងបឹងកក់២ ក្នុងខ័ណ្ឌទួលគោក ។

**ប្រការ៣** : ការផ្លាស់ប្តូរទីតាំងឱសថស្ថានរង ប្រភេទ (ក) និង (ខ) អាចអនុញ្ញាតបាន លុះត្រាតែទីតាំងចាស់ឈប់មានសកម្មភាព ។ ការផ្លាស់ប្តូរអ្នកទទួលខុសត្រូវ , ការផ្លាស់ប្តូរទីតាំង និងឈ្មោះឱសថស្ថានរង នឹងមិនត្រូវបាន អនុញ្ញាតជូនក្នុងពេលតែ១ឡើយ ។

ទីស្តីការរដ្ឋមន្ត្រីក្រសួងសុខាភិបាល,លេខ ១៥១-១៥៣ វិថីកម្ពុជាក្រោម ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៤២៦ ០៣៤ / ៤២៦ ៨៤១ ទូរស័ព្ទ: (៨៥៥-២៣) ៧២២ ៩៣៣

**ប្រការ៤** : ឱសថស្ថានរងប្រភេទ (ក) និង (ខ) ដែលបច្ចុប្បន្នបានទទួលច្បាប់អនុញ្ញាតឱ្យបើករួចហើយនោះ ត្រូវបានរក្សាសិទ្ធិឱ្យបន្តសុពលភាពធ្វើអាជីវកម្មដដែល ។

ក្នុងករណីមានការសុំប្តូរទីតាំង ឱសថស្ថានរងខាងលើ ត្រូវអនុវត្តតាមល័ក្ខខ័ណ្ឌថ្មី ដែលមានចែងក្នុងប្រការ១, ប្រការ២ និងប្រការ៣ នៃប្រកាសនេះ ។

**ប្រការ៥** : បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៦** : អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល , អគ្គាធិការដ្ឋាន , ខុទ្ទកាល័យក្រសួងសុខាភិបាល , នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង និងមន្ទីរសុខាភិបាលរាជធានីភ្នំពេញ មានភារកិច្ចអនុវត្ត តាមប្រកាសនេះ ឱ្យមានប្រសិទ្ធភាព តាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

បណ្ឌ. នុត សុខុម

<u>ចំលងជូន</u> :

-ខុទ្ទកាល័យរដ្ឋសភា
-ខុទ្ទកាល័យគណៈរដ្ឋមន្ត្រី
-អគ្គនាយកដ្ឋានរដ្ឋបាល-ហិរញ្ញវត្ថុ
-តាមប្រការ ៦
-កាលប្បវត្តិ
-ឯកសារ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**
លេខ : ១.៨០ ប្រក

# ប្រកាស
## ស្តីពី
## ការរៀបចំគណៈកម្មការជំរឿន និង គ្រប់គ្រងជនបរទេស

## សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ ន.ស.៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការ រៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ន.ស.រកត ០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ន.ស.រកត ០១៩៦-០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ ០៥ ន.ស.៩៤ ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីអន្តោប្រវេសន៍
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ/បក ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញសេចក្តីសំរេច លេខ ០៩១ សសរ ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០០៤ របស់ក្រសួងមហាផ្ទៃ ស្តីពីការកែសំរួល និង ផ្លាស់ប្តូរសមាសភាពនៃគណៈកម្មការ យុទ្ធនាការជំរឿនស្ថិតិជនបរទេស
- យោងតាមការងារចាំបាច់

## សំ រេ ច

**ប្រការ ១ :** បង្កើតគណៈកម្មការជំរឿន និង គ្រប់គ្រងជនបរទេស ក្រសួងមហាផ្ទៃ មានសមាសភាពដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១- ឯកឧត្តម រដ្ឋលេខាធិការ | **ឯម** | **សំអាន** | សហប្រធាន |
| ២- ឯកឧត្តម រដ្ឋលេខាធិការ | **ខាន់** | **សាវឿន** | សហប្រធាន |
| ៣- ឯកឧត្តម នាយឧត្តមសេនីយ៍ | **ហុក** | **ឡុងឌី** | អនុប្រធាន |
| ៤- ឯកឧត្តម អគ្គនាយករដ្ឋបាល | **សក់** | **សេដ្ឋា** | អនុប្រធាន |

| | | | |
|---|---|---|---|
| ៥- ឯកឧត្តម ឧត្តមសេនីយ៍ឯក | ស្វ | ផន | អនុប្រធាន |
| ៦- ឯកឧត្តម ឧត្តមសេនីយ៍ឯក | យូ | ស៊ុនឡុង | សមាជិក |
| ៧- ឯកឧត្តម ឧត្តមសេនីយ៍ឯក | ម៉ៅ | ច័ន្ទតារា | សមាជិក |
| ៨- ឯកឧត្តម ឧត្តមសេនីយ៍ឯក | សុខ | ផល | សមាជិក |
| ៩- ឯកឧត្តម | ប៉ុល | លឹម | សមាជិក |
| ១០-លោកឧត្តមសេនីយ៍ត្រី | កៀត | ច័ន្ទថារិទ្ធ | សមាជិក |
| ១១-លោកវរៈសេនីយ៍ឯក | ហុង | ប៊ុនហ៊ាង | សមាជិក |
| ១២-លោកវរៈសេនីយ៍ឯក | រស់ | នឹមសារុន | សមាជិក |
| ១៣-លោកវរៈសេនីយ៍ឯក | ព្រហ្ម | វិមល | សមាជិក |

**ប្រការ ២ :** គណៈកម្មការនេះមានភារៈកិច្ច :

១- ពិនិត្យ បូកសរុបលទ្ធផលអនុវត្តផែនការលេខ ០១១ ផក ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០០២ របស់ក្រសួងមហាផ្ទៃ ស្តីពីយុទ្ធនាការជំរឿនស្ថិតិជនបរទេស ពិចារណាផ្តើមយោបល់ ដើម្បីស្នើសុំគោលការណ៍រាជរដ្ឋាភិបាល ដោះស្រាយចំពោះជនបរទេសបែបអន្តោប្រវេសន្ត ដែលបានស្រង់ស្ថិតិ តាមរយៈផែនការនេះ ។

២- ចាត់វិធានការអនុវត្តគោលការណ៍របស់រាជរដ្ឋាភិបាល ក្នុងការពិនិត្យសំរេចទទួលស្គាល់ ឬ មិនទទួលស្គាល់ ជាជនបរទេសអន្តោប្រវេសន្តនៅកម្ពុជា ។

៣- ណែនាំ ដឹកនាំ អនុវត្តសេចក្តីណែនាំលេខ ០០២ សណន ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០០៣ របស់ក្រសួងមហាផ្ទៃ ស្តីពីការបង្កើនការងារគ្រប់គ្រងជនបរទេស ។

៤- ណែនាំ ដឹកនាំ ការត្រួតពិនិត្យវត្តមានជនបរទេស និង ការធ្វើការរបស់ជនបរទេសស្របតាមច្បាប់ស្តីពីអន្តោប្រវេសន៍ និង ច្បាប់ការងារ ។

៥- ចាត់វិធានការដោះស្រាយចំពោះជនបរទេស ដែលលបលាក់ចូលមកកម្ពុជាដោយខុសច្បាប់ ឬ រំលោភលើបទបញ្ញត្តិច្បាប់អន្តោប្រវេសន៍ ដោយស្របតាមច្បាប់ស្តីពីអន្តោប្រវេសន៍ ។

៦- ពិនិត្យ កសាងបទដ្ឋាននានា ពាក់ព័ន្ធដល់ការអនុវត្តន៍ច្បាប់ស្តីពីអន្តោប្រវេសន៍ និង ច្បាប់ស្តីពីសញ្ជាតិ ដែលមិនទាន់បានចែង ។

**ប្រការ ៣ :** គណៈកម្មការជំរឿន និង គ្រប់គ្រងជនបរទេសក្រសួងមហាផ្ទៃ មានលេខាធិការដ្ឋាន និង ក្រុមអចិន្ត្រៃយ៍ ជាជំនួយការ ដែលមានសមាសភាពដូចខាងក្រោម :

**ក-ក្រុមលេខាធិការដ្ឋាន :**

| | | | |
|---|---|---|---|
| ១- ឯកឧត្តម ឧត្តមសេនីយ៍ឯក | សុខ | ផល | ប្រធាន |
| ២- លោកឧត្តមសេនីយ៍ត្រី | កៀត | ច័ន្ទថារិទ្ធ | អនុប្រធាន |

៣- លោកវរៈសេនីយ៍ឯក **ហុង ប៊ុនហ៊ាង** អនុប្រធាន

៤- លោកវរៈសេនីយ៍ឯក **ព្រហ្ម វិមល** សមាជិក

៥- លោកវរៈសេនីយ៍ឯក **ពិន ពិសិដ្ឋ** សមាជិក

៦-លោកវរៈសេនីយ៍ទោ **ឆន វត្ថា** សមាជិក

**ខ-ក្រុមអ្នកច្បាប់ :**

១-ឯកឧត្តម **ប៉ុល លឹម** ប្រធាន

២-លោកឧត្តមសេនីយ៍ត្រី **ប្រុក សារឿន** អនុប្រធាន

៣-លោកវរៈសេនីយ៍ឯក **ខិន វ៉ាន់ដេន** សមាជិក

៤-លោកវរៈសេនីយ៍ឯក **ជៅត សំរ៉ាង** សមាជិក

៥-លោកវរៈសេនីយ៍ទោ **វៀម សារិន** សមាជិក

**ប្រការ ៤ :** គណៈកម្មការជំរឿន និង គ្រប់គ្រងជនបរទេសក្រសួងមហាផ្ទៃ មានសិទ្ធប្រើប្រាស់ត្រាក្រសួងមហាផ្ទៃ ។

**ប្រការ ៥ :** បង្កើតគណៈកម្មការជំរឿន និង គ្រប់គ្រងជនបរទេសនៅថ្នាក់ខេត្ត-ក្រុង គ្រប់ខេត្ត និង ក្រុង ដែលមានសមាសភាព ដូចខាងក្រោម :

១- ឯកឧត្តម អភិបាលខេត្ត-ក្រុង ប្រធាន

២- ឯកឧត្តម អភិបាលរងទី១ ខេត្ត-ក្រុង អនុប្រធានទី១

៣- លោកនាយស្នងការនគរបាលខេត្ត-ក្រុង អនុប្រធាន

៤- លោកនាយស្នងការរងទី ១ នគរបាលខេត្ត-ក្រុង អនុប្រធាន

៥- លោកនាយការិយាល័យកណ្ដាលសន្តិសុខ សមាជិក

៦- លោកនាយការិយាល័យជនបរទេស សមាជិក

៧- លោកអភិបាលខ័ណ្ឌ-ស្រុកទាំងរស់ សមាជិក

រាល់ការចុះហត្ថលេខារបស់ប្រធាន ត្រូវមានហត្ថលេខាសង្ខេបរបស់អនុប្រធានទី១ ។

**ប្រការ ៦ :** គណៈកម្មការជំរឿន និង គ្រប់គ្រងជនបរទេសខេត្ត-ក្រុង មានភារៈកិច្ច :

១- ពិនិត្យឡើងវិញលទ្ធផលនៃការធ្វើយុទ្ធនាការជំរឿនស្ថិតិជនបរទេស តាមសេចក្ដីណែនាំអនុវត្តផែនការលេខ ០១១ ផក រាយការណ៍ពីការប្រែប្រួលជូនគណៈកម្មការជំរឿន និង គ្រប់គ្រងជនបរទេសក្រសួង ។

២- ចាត់វិធានការអនុវត្តសេចក្ដីណែនាំលេខ ០០២ សណន ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០៣ របស់ក្រសួងមហាផ្ទៃ ស្ដីពីការបង្កើនការងារគ្រប់គ្រងជនបរទេស ។

៣- ចាត់វិធានការ ត្រួតពិនិត្យវត្តមានជនបរទេស និង ការធ្វើការងាររបស់ជនបរទេស នៅក្នុងភូមិសាស្ត្រខេត្ត-ក្រុងទទួលខុសត្រូវរបស់ខ្លួន ស្របតាមច្បាប់ស្តីពីអន្តោប្រវេសន៍ និង ច្បាប់ការងារ និងរាយការណ៍មកគណៈកម្មការជំរឿន និង គ្រប់គ្រងជនបរទេសក្រសួងមហាផ្ទៃ ។

៤- អនុវត្តការងារផ្សេងៗទៀត តាមទិសដៅ និង ការណែនាំរបស់ គណៈកម្មការជំរឿន និង គ្រប់គ្រងជនបរទេសក្រសួងមហាផ្ទៃ ។

**ប្រការ ៧ :** គណៈកម្មការជំរឿន និង គ្រប់គ្រងជនបរទេសខេត្ត-ក្រុង មានក្រុមលេខាធិការជាជំនួយការ ។ សមាសភាពក្រុមលេខាធិការ អាស្រ័យដោយប្រធានគណៈកម្មការជំរឿន និងគ្រប់គ្រងជនបរទេសខេត្ត-ក្រុង ជ្រើសតាំង ។

**ប្រការ ៨ :** រាល់បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៩ :** អគ្គលេខាធិការដ្ឋាន អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានរដ្ឋបាល អគ្គាធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាល និងនគរបាល ក្រុមអ្នកច្បាប់ក្រសួងមហាផ្ទៃ ឯកឧត្តមអភិបាលខេត្ត-ក្រុង គណៈ-កម្មការយុទ្ធនាការជំរឿនស្ថិតិជនបរទេស ស្ថាប័នពាក់ព័ន្ធក្រោមឱវាទក្រសួងមហាផ្ទៃ និងអស់លោកដែលមានឈ្មោះក្នុងប្រការ ១,៣,៥,៧ និង៩ ត្រូវអនុវត្តប្រកាសនេះអោយមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ៧ ឆ្នាំ២០០៤

សហរដ្ឋមន្ត្រី

ស ខេង

នាយឧត្តមសេនីយ៍ ស ខេង

ចម្លងជូន :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

"ដើម្បីជូនជ្រាប"
- ដូចប្រការ ១,៣,៥,៧ និង ៩

"ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ.

**ព្រះរាជាណាចក្រកម្ពុជា**
**Kingdom of Cambodia**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Nation Religion King**

**ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា**
**និងអធិការកិច្ច**
**Ministry of National Assembly-Senate Relations and Inspection**

លេខ : ៩៧៩/០៤ ទ.រ.ព.អ ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី០៦ ខែ០៩ ឆ្នាំ២០០៤

# ប្រកាស
## ស្តីពី
## ការតែងតាំងនាយកកម្មវិធីកន្សោមអាទិភាពរួមនាំងក្រុមការងារ ដើម្បីដឹកនាំ គ្រប់គ្រង និងជំរុញដំណើរការកន្សោមអាទិភាព

---

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩/០៩ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ការបង្កើតក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៩០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពី លក្ខន្តិកៈ មូលដ្ឋាន និងក្រាក់បន្ទាប់បន្សំនៃលក្ខន្តិកៈរបស់មន្ត្រីរាជការស៊ីវិល
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច
- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០០២ ស្តីពី ការកែសម្រួលប្រាក់បំណាច់មុខងាររបស់មន្ត្រីរាជការស៊ីវិល និងប្រាក់កំរៃគរុកោសល្យក្នុងវិស័យអប់រំ
- បានឃើញអនុក្រឹត្យលេខ ៨៣ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០០២ ស្តីពី ការបង្កើត និងដាក់ឱ្យដំណើរការកម្មវិធីកន្សោមអាទិភាព
- តាមការចាំបាច់របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ។

## ស ំ រេ ច

**ប្រការ១ ..**

ត្រូវបានតែងតាំង **ឯកឧត្តម រដ្ឋលេខាធិការ ច្រាត់ ហាម** ជានាយកកម្មវិធីកន្សោម ដើម្បីដឹកនាំ គ្រប់គ្រង និង ជំរុញដំណើរការកន្សោមអាទិភាព នៅក្នុងក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និង អធិការកិច្ច ។

**ប្រការ២ ..**

នាយកកម្មវិធីកន្សោមអាទិភាពនេះ មានតួនាទីភារកិច្ច ÷

- ដឹកនាំ គ្រប់គ្រង និងជំរុញដំណើរការកន្សោមអាទិភាពនៅក្នុងក្រសួង ។
- ធានាឱ្យការងារប្រចាំថ្ងៃតាមបណ្ដាផ្នែក មានដំណើរការជាប្រក្រតី និងបញ្ចៀស ឬកាត់បន្ថយ រាល់ហានិភ័យផ្សេងៗ ដែលអាចកើតឡើង ។
- រៀបចំក្រុមការងារផ្ទៃក្នុងសំរាប់កំណត់អត្តសញ្ញាណបេសកកម្មអាទិភាព កំណត់អាទិភាពនៃបេសកកម្មអាទិភាព រៀបចំសំណើសុំដាក់ឱ្យដំណើរការកន្សោមអាទិភាព វាយតម្លៃពាក្យសុំជ្រើសរើសចូលជាសមាជិកកន្សោមអាទិភាព និងបំពេញភារកិច្ចផ្សេងៗទៀត តាមការចាំបាច់ ។
- ធ្វើរបាយការណ៍ស្ដីពីភាពជឿនលឿននៃការអនុវត្តកម្មវិធីកន្សោមអាទិភាពរៀងរាល់ខែ និងត្រីមាស ជូនប្រធានស្ថាប័ន និងជូនក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ។

**ប្រការ៣ ..**

ត្រូវបានតែងតាំងសមាជិកក្រុមការងារ ស្ថិតក្រោមការគ្រប់គ្រងរបស់នាយកកម្មវិធីកន្សោមអាទិភាព ដែលមានសមាសភាពដូចតទៅ ÷

| | | | | |
|---|---|---|---|---|
| ១-លោក | **ទេន់ វឌ្ឍនៈ** | ឋានៈ | **អគ្គនាយករង** | សមាជិក |
| ២-លោក | **កែវ គន់** | ឋានៈ | **អនុប្រធាននាយកដ្ឋាន** | សមាជិក |
| ៣-លោក | **ច័ន្ទ ចរិយា** | ឋានៈ | **អនុប្រធាននាយកដ្ឋាន** | សមាជិក |
| ៤-លោក | **ស៊ិន សុប្រិយ៉ានី** | ឋានៈ | **ប្រធានការិយាល័យ** | សមាជិក |
| ៥-លោក | **មាស សុគន្ធ** | ឋានៈ | **អនុប្រធានការិយាល័យ** | សមាជិក |
| ៦-កញ្ញា | **ហេង ពេជ្រចិន្តា** | ឋានៈ | **មន្ត្រី** | សមាជិក |
| ៧-កញ្ញា | **សាន សម្បត្តិ** | ឋានៈ | **មន្ត្រី** | សមាជិក |

**ប្រការ៤ ..**

សមាជិកក្រុមការងារនេះ មានភារកិច្ចដូចតទៅ ÷

- កំណត់បេសកកម្មជាអាទិភាព ដែលត្រូវប្រើប្រាស់កញ្ចប់ថវិកាកន្សោមអាទិភាព ។ បេសកម្មជាអាទិភាពទាំងឡាយ ត្រូវរៀបចំឡើងឱ្យស្របនឹងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការកាត់បន្ថយភាពក្រីក្រ កំណែទម្រង់តាមវិស័យ និងការដាក់ពង្រាយមន្ត្រីរាជការ ។ គំរោងបេសកកម្មនេះរួមមានឈ្មោះបេសកកម្មការងារ តម្រូវការចំនួនមន្ត្រីរាជការ និងថេរវេលានៃការអនុវត្តបេសកកម្មជាអាទិភាពនីមួយៗ ។
- រៀបចំឯកសារគោលការណ៍ ឯកសារណែនាំ ព្រមទាំងឯកសារផ្សេងៗទៀត និងលើកផែនការផ្សព្វផ្សាយ និងបណ្តុះបណ្តាល ជូនមន្ត្រីកន្សោមអាទិភាពនៅតាមបណ្តាអង្គភាពចំណុះក្រសួង ឱ្យបានជ្រួតជ្រាប អំពីទស្សនទាន និង គោលការណ៍នៃកម្មវិធីកន្សោមអាទិភាព ។
- សម្របសម្រួល និង ផ្តល់យោបល់លើការងារបច្ចេកទេស ជូននាយកគ្រប់គ្រងកម្មវិធីកន្សោមអាទិភាពរបស់ក្រសួង ។

សិក្សាផែនការការងារ និង សំណើសុំអនុវត្តបេសកកម្មអាទិភាពរបស់អង្គភាពចំណុះក្រសួង ដើម្បីលើកយោបល់ជូននាយកកម្មវិធីកន្សោមអាទិភាពក្រសួង ពិនិត្យ និង សម្រេច ។

ផ្តល់យោបល់លើការងារបច្ចេកទេសដល់នាយកកម្មវិធីកន្សោមអាទិភាពក្រសួង ដើម្បីនាយកកម្មវិធី កន្សោមអាទិភាពក្រសួង ងាយស្រួលរាយការណ៍ជូនដល់ គណៈកម្មការជ្រើសរើសសមាជិកកន្សោមអាទិភាព គណៈកម្មការតាមដានត្រួតពិនិត្យការអនុវត្តកម្មវិធីកន្សោមអាទិភាព និងគណៈកម្មការសវនកម្ម និងអធិការកិច្ច អនុវត្តកម្មវិធីកន្សោមអាទិភាព ។

រៀបចំការប្រជុំ ដើម្បីផ្លាស់ប្តូរបទពិសោធន៍ទៅវិញទៅមក រវាងកន្សោមអាទិភាពនៅតាមបណ្តាអង្គភាពចំណុះក្រសួង សំដៅលើកកំពស់សមត្ថភាពរបស់កន្សោមអាទិភាពនីមួយៗ ។

ផ្សព្វផ្សាយពត៌មាន និង រាយការណ៍ ស្តីពី វឌ្ឍនភាព នៃការអនុវត្តកម្មវិធីរបស់កន្សោមអាទិភាពនីមួយៗ តាមព្រឹត្តិប័ត្រ វិបសាយ ការប្រជុំ ឬ សិក្ខាសាលា ។

បំពេញភារកិច្ចផ្សេងៗទៀត ដែលនាយកម្មវិធីកន្សោមអាទិភាពក្រសួងប្រគល់ជូន ដើម្បីឱ្យការអនុវត្ត កម្មវិធីកន្សោមអាទិភាពប្រព្រឹត្តទៅបានល្អ ។

**ប្រការ៥ ៈ**

សមាជិកក្រុមការងារសំរាប់ជំរុញដំណើរការកន្សោមអាទិភាព ត្រូវបំពេញកិច្ចសន្យាការងារសំរាប់រយៈពេល ១២ ខែ ដោយគិតចាប់ពីថ្ងៃប្រកាសដាក់ឱ្យដំណើរការ ជាផ្លូវការតទៅ ។

ការបន្តកិច្ចសន្យាជាថ្មី ឬការបញ្ឈប់កិច្ចសន្យា គឺអាស្រ័យទៅលើសមត្ថភាពក្នុងការបំពេញភារកិច្ចរបស់សមាជិកម្នាក់ៗ និងការចាំបាច់នៃបេសកកម្ម ។

**ប្រការ៦ .-**

នាយកកម្មវិធីកន្សោមអាទិភាព ត្រូវវាយតម្លៃសមត្ថភាពអនុវត្តការងាររបស់សមាជិកម្នាក់ៗ ជារៀងរាល់ខែ ។

សមាជិកដែលត្រូវបានវាយតម្លៃថា មានគុណសម្បត្តិខ្ពស់ ឬគ្មានសមត្ថភាពក្នុងការបំពេញភារកិច្ច អាចបន្ត សមាជិកភាពដោយបំពេញកិច្ចសន្យាជាថ្មី ឬត្រូវបានបញ្ចប់សមាជិកភាពដោយក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល តាមសំណើរបស់នាយកកម្មវិធីកន្សោមអាទិភាព ។

**ប្រការ៧ .-**

សមាជិកកន្សោមអាទិភាពសំរាប់កន្សោមអាទិភាព ដែលមិនបានទទួលប្រាក់បំណាច់តាមមាត្រា ១៦ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពី បៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំ នៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល និងតាមមាត្រា ៣ នៃអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០០២ ស្តីពី ការកែសំរួលប្រាក់បំណាច់មុខងាររបស់មន្ត្រីរាជការ និងប្រាក់កំរៃគរុកោសល្យក្នុងវិស័យអប់រំ ត្រូវបានទទួលប្រាក់ឧបត្ថម្ភពិសេសបន្ថែមលើសមត្ថភាពអនុវត្តការងារ នៅតាមគោលការណ៍ នៃកម្មវិធីកន្សោមអាទិភាព ។

**ប្រការ៨ .-**

គ្រប់អង្គភាពចំពោះក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងប្រការ ១ និងប្រការ ៣ ខាងលើ ត្រូវអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។ /.

ម៉ែន សំអន

**ចម្លងជូន :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល
- អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ដូចប្រការ ៨
- ឯកសារ-កាលប្បវត្តិ